**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤០៨៧ មស.សរ៧

# សេចក្តីជូនដំណឹង
# ស្តីពី
# ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ប្រចាំឆ្នាំ២០២១
# ជូនមន្ត្រីរាជការស៊ីវិល

យោងព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជានិងលិខិតលេខ ៥៧៤៧ មស.គរ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ ឋានន្តរស័ក្តិ ថ្នាក់កិត្តិយស និងដំឡើងឋានន្តរស័ក្តិ ថ្នាក់ តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល របស់ក្រសួងមុខងារសាធារណៈ ។

ក្រសួងមុខងារសាធារណៈ មានកិត្តិយស សូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា សម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ២០២១ គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំសំណុំឯកសារការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួនតាមវេនជ្រើសរើស និងវេនអតីតភាពការងារឱ្យបានច្បាស់លាស់ ទាន់ពេលវេលា និងមានសង្គតិភាព ដោយត្រូវផ្តល់សំណុំឯកសារមកឱ្យក្រសួងមុខងារសាធារណៈ **យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១** ដើម្បីឱ្យក្រសួងមុខងារសាធារណៈមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និងផ្តល់ទិដ្ឋាការជូនបានទាន់ពេលវេលា ។

ចំពោះបញ្ជីរាយនាមមន្ត្រីរាជការស៊ីវិល ដែលត្រូវស្នើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ត្រូវមានចុះហត្ថលេខាសង្ខេប អ្នកទទួលខុសត្រូវ និងមានបោះត្រាក្រសួង ស្ថាប័ននៅគ្រប់ទំព័រ ។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ តាមការគួរ ។

ថ្ងៃអង្គារ ១ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

ព្រុំ សុខា

**ចម្លងជូន**
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh